## Asking for directions 1



### អ្នកមិនស្គាល់គ្នាដែលជួបតាមផ្លូវ

សោភា៖ បង សុំសួរតិច។ នៅម្តុំហ្នឹងមានហាងកាហ្វេអាម៉ាហ្សូនអត់បង?
អ្នកតាមផ្លូវ ១៖ អាម៉ាហ្សូន?... នៅមុខនោះដូចមានហាងកាហ្វេមួយ តែមិនដឹងឈ្មោះអីអេ៎នៀក ...
អ្នកតាមផ្លូវ ២៖ ហ្នឹងហើយ កាហ្វេអាម៉ាហ្សូន! អគារពណ៌ខ្មៅ ហើយបៃតងតិចៗហ្នឹងមែន?
សោភា៖ ចា៎ស។ នៅមុខហ្នឹងមែនបង?
អ្នកតាមផ្លូវ ២៖ ហ្នឹងហើយ។ ទៅមុខ ដល់ភ្លើងស្តុប ហើយបត់ស្តាំទៅ ឃើញហើយ។
សោភា៖ អូ ចា៎ស អរគុណច្រើនបង។

### មិត្តភក្តិ

សោភា៖ វណ្ណា! វណ្ណាដឹងថាក្រសួងអប់រំនៅម្តុំណាអេ៎?
វណ្ណា៖ ដឹងតាស។ នៅតាមផ្លូវនរោត្តមយើងនេះ។
សោភា៖ ផ្លូវនរោត្តម ... ផ្លូវឈ្មោះស្រដៀងគ្នា មិនដឹងផ្លូវណាទេនៀក ...
វណ្ណា៖ ចុះសោភាឯងស្គាល់សាលាចតុមុខអត់? នៅតាមផ្លូវជាមួយគ្នាហ្នុង។
សោភា៖ ឥឡូវ ឧទាហរណ៍ថាសាលាចតុមុខនៅនេះ ក្រសួងហ្នឹងនៅខាងណាវិញ? ខាងឆ្វេង ឬក៏ខាងស្តាំ?
វណ្ណា៖ នៅទិសសំដៅទៅវិមានឯករាជ្យ។
សោភា៖ អូ! យល់ហើយ។

| | |
|---|---|
| សោភា / វណ្ណា | female / male Cambodian names |
| តិច | phrase-final: makes a request more polite |
| អាម៉ាហ្សូន | Amazon (a coffee chain in South-East Asia) |
| អេ៎ | spoken form of the question or negation particle ទេ |
| នៀក | spoken forms of នេះ = this |
| ចា៎ស | same as ចាស, but written with a diacritic to indicate high intonation |
| ភ្លើងស្តុប | traffic light |
| ក្រសួងអប់រំ | Ministry of Education |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| តាស | particle in final position used to affirm the preceding |
| នរោត្តម | Norodom (king of Cambodia 1860—1904) |
| ចតុមុខ | Chattomukh (junction of four rivers at Phnom Penh), also spelled ចតុម្មុខ |
| វិមានឯករាជ្យ | Independence Monument (in Phnom Penh) |

## Cultural notes

មាត់ជាផ្លូវ គឺជាពាក្យស្លោកដែលប្រជាជនខ្មែរឧស្សាហ៍ប្រើណាស់។ វាមានន័យថា នៅពេលយើងមិនដឹង ឬមិនយល់អ្វីមួយ យើងគប្បីសួរទៅអ្នកដទៃ ដើម្បីឲ្យគេបង្ហាញផ្លូវថាតើត្រូវទៅណាឬធ្វើអ្វីបន្ទាប់ទៀត។ ពាក្យស្លោកមួយទៀត គឺ ចោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់ មានន័យថា គ្រាន់តែសួរអ្នកដទៃអំពីអ្វីដែលខ្លួនមិនដឹង ឬមិនចេះ នឹងមិនធ្វើឲ្យអាប់ឱនកិត្តិយសឬខ្មាសគេអ្វីឡើយ។

| | |
|---|---|
| មាត់ជាផ្លូវ | the mouth is the "way" |
| ពាក្យស្លោក | saying |
| គប្បី | should, ought to |
| អាប់ឱនកិត្តិយស | to get humiliated |
| ខ្មាសគេ | to feel ashamed |

## Additional dialogue

សោភា៖ ពូ ខ្ញុំសុំសួរតិច។ ទៅផ្សារអ៊ីអន តាមផ្លូវណាវិញទៅពូ?
អ្នកតាមផ្លូវ៖ ជិះតាមនេះក៏បាន ជិះតាមនោះក៏បាន។ ជិះតាមនេះទៅលឿនជាង។
សោភា៖ មួយណាស្រួលរកជាងពូ?
អ្នកតាមផ្លូវ៖ ជិះតាមនោះស្រួលរកជាង ប៉ុន្តែវៀងឆ្ងាយតិច។
សោភា៖ ចាស អត់អីអេ៎ពូ។ អីចឹង ខ្ញុំត្រូវជិះទៅត្រង់មែន ពូ?
អ្នកតាមផ្លូវ៖ បាទ ជិះទៅមុខត្រង់រហូតដល់ផ្លូវទាល់ហើយបត់ឆ្វេង ហើយជិះរហូតទៀតទៅ ឃើញហើយ។

| | |
|---|---|
| ពូ | uncle; respectful term to address elder men |
| ផ្សារអ៊ីអន | Aeon mall (a mall in Phnom Penh) |
| វៀង + adj. + តិច | a bit + adj. |
| ... មែន? | ... right? |
| ផ្លូវទាល់ | dead end |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.